WWF

ANNUAL REPORT

KH

2014



© Nick Cox / WWF-Cambodia

# ការអភិរក្ស និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ៖ ការពុះពារគ្រប់ឧបសគ្គដើម្បីបង្កើតឲ្យមានតុល្យភាព នៅប្រទេសកម្ពុជា

របាយការណ៍របស់អង្គការ WWF-កម្ពុជា
ប្រចាំឆ្នាំ ២០១៣ - ២០១៤



© Fletcher and Baylis / WWF-Cambodia

# កម្មវិធីមហាតំបន់មេគង្គរបស់អង្គការ WWF

មហាតំបន់ទន្លេមេគង្គគឺជាទីកន្លែងរតនៈសម្បត្តិជីវសាស្ត្រដែលសម្បូរណ៍ទៅដោយទីជម្រកដែលមិនទាន់រងនូវការបំផ្លិចបំផ្លាញ និងមានតម្លៃបំផុតនៅលើភពផែនដីយើងនេះ។

តំបន់នេះគឺជាលំនៅដ្ឋានរបស់ក្រុមជនជាតិដើមភាគតិចប្រមាណជាង ១០០ ក្រុមផ្សេងគ្នា និងជាទីជម្រករបស់រុក្ខជាតិប្រមាណជាង ២០,០០០ ប្រភេទ សត្វស្លាបជាង ១,២០០ ប្រភេទ ថលជលិកសត្វ (សត្វដែលអាចរស់នៅក្នុងទឹកក៏បាន លើគោកក៏បាន) និង ឧរង្គសត្វ (សត្វដែលបម្លាស់ទីដោយការ វា ឬ ល្វូន) ជាង ៨០០ ប្រភេទ ថនិកសត្វ (ប្រភេទសត្វដែលចិញ្ចឹមកូនដោយការបំបៅដោះ) ជាង ៤៣០ ប្រភេទ និងមច្ឆាចំនួនជាង ១៣០០ ប្រភេទ។

តំបន់នេះកំពុងប្រឈមទៅនឹងការគំរាមកំហែងដ៏ធ្ងន់ធ្ងរ។ គម្រោងទំនប់វារីអគ្គិសនីខ្នាតធំ ការអភិវឌ្ឍន៍ដែលកំពុងតែរាលដាលគ្រប់ទីកន្លែង ការប្រែប្រួលអាកាសធាតុ ការជួញដូរសត្វព្រៃខុសច្បាប់និងការកាប់បំផ្លាញព្រៃឈើកំពុងបង្កការគម្រាមកំហែងដល់ជីវចម្រុះនៅក្នុងតំបន់នេះ និងលទ្ធភាពទ្រទ្រង់របស់តំបន់នេះដល់ការរស់នៅរបស់ប្រជាជនចំនួន ៣០០ លាននាក់ដែលកំពុងពឹងអាស្រ័យលើធនធានធម្មជាតិ។ ការបន្តបាត់បង់ប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់នេះធ្វើឲ្យប្រភេទសត្វនិមិត្តរូបមួយចំនួន រួមមាន៖ សត្វខ្លាធំ សត្វដំរី ខ្លាឃ្មុំ ត្រីរាជ និងសត្វផ្សោតទន្លេមេគង្គប្រឈមទៅនឹងការផុតពូជ។ ប៉ុន្តែយើងនៅតែមានក្តីសង្ឃឹម។ អង្គការ WWF កំពុងបំពេញការងារអភិរក្សយ៉ាងពេញលេញនៅក្នុងតំបន់នេះ។ កម្មវិធីមហាតំបន់មេគង្គដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលការងារអភិរក្សនៅក្នុងប្រទេសចំនួនប្រាំដែលមានការិយាល័យរបស់ខ្លួន ក្នុងនោះរួមមាន៖ ប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសភូមា ប្រទេសថៃ និង ប្រទេសវៀតណាម ហើយបានពង្រីកវិសាលភាពទីតាំងអភិរក្សរបស់ខ្លួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍លើផ្ទៃដីព្រៃ និង ដងទន្លេក្នុងទំហំសរុប ៦០០០០ គីឡូម៉ែត្រការ៉េដែលជាទីកន្លែងមានតម្លៃជីវចម្រុះខ្ពស់ និងមានសារៈសំខាន់ខាងផ្នែកអភិវឌ្ឍសេដ្ឋកិច្ច។

ដោយមានកិច្ចសហការជាមួយរដ្ឋាភិបាល ដៃគូអាជីវកម្ម និងសង្គមស៊ីវិល យើងកំពុងនាំមុខក្នុងការការពារប្រភេទសត្វព្រៃគ្រប់ប្រភេទ លើកទឹកចិត្តឲ្យមានការគ្រប់គ្រងព្រៃឈើ និងអនុផលព្រៃឈើ និងលើកកម្ពស់ការប្រើប្រាស់ធនធានទឹកសាបប្រកបដោយនិរន្តរភាព។ ជាងនេះទៅទៀត យើងកំពុងជួយសហគមន៍ និងរដ្ឋាភិបាលឲ្យចេះបន្សាំខ្លួនទៅនឹងការបម្រែបម្រួលអាកាសធាតុ និងជួយធ្វើឲ្យការអភិរក្ស និងអភិវឌ្ឍមានតុល្យភាព។

# បេសកកម្មរបស់អង្គការ WWF ប្រចាំកម្ពុជា

បេសកកម្មអង្គការ WWF នៅប្រទេសកម្ពុជា គឺធ្វើយ៉ាងណាដើម្បីធានាអោយមានការចូលរួម និងការគាំទ្រពីសំណាក់ប្រជាពលរដ្ឋទាំងអស់ ដើម្បីអភិរក្សជីវៈចម្រុះដ៏សម្បូរបែបនៅក្នុងប្រទេសតាមរយៈការលើកទឹកចិត្តឲ្យប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តភាព។ អង្គការ WWF - កម្ពុជា បានជម្រុញឲ្យមានឱកាសថ្មីសម្រាប់ជាប្រយោជន៍ដល់ប្រជាជនទាំងអស់ក្នុងការលើកកម្ពស់ជីវភាពរស់នៅក្នុងតំបន់ដើម្បីរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រក្នុងព្រះរាជាណាចក្រកម្ពុជា។

# មាតិកា


**ដៃគូអភិរក្ស** ១

**សារលិខិតពីនាយកអង្គការ WWF ប្រចាំប្រទេសកម្ពុជា** ២

**យុទ្ធសាស្ត្រអភិរក្សរបស់អង្គការ WWF ប្រចាំប្រទេសកម្ពុជា** ៣

**ការការពារបណ្តុំព្រៃល្បោះរបស់ប្រទេសកម្ពុជា** ៤

**សកម្មភាពក្នុងឆ្នាំ ២០១៣ - ២០១៤** ៥-៦

ការគាំទ្រដល់អ្នកការពារធនធានធម្មជាតិ ៥

ការរីកលូតលាស់ឧស្សាហកម្មផ្តៅប្រកបដោយនិរន្តរភាព ៥

ការលើកកម្ពស់សេដ្ឋកិច្ចបៃតង ៦

ការកែលំអរបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ៦

ការកំណត់លើការការពារព្រៃលិចទឹកនៃទន្លេមេគង្គ ៦

**តើអ្វីទៅជាតំបន់ទេសភាព ?** ៧

**កិច្ចការពារតំបន់ទន្លេមេគង្គ** ៨

**ការអភិរក្សសត្វ និងការចូលរួមរបស់ប្រជាជន** ៩-១០

ការស្តារចំនួនសត្វខ្លាឡើងវិញនៅក្នុងប្រទេសកម្ពុជា ៩

ការការពារសត្វផ្សោតទន្លេមេគង្គ ១០

ទន្លេមេគង្គដ៏អាថ៌កំបាំង ១០

**សកម្មភាពរួមគ្នាសម្រាប់ពេលអនាគត** ១១

បញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនី ដន សាហុង ១១

យុវជនដឹកនាំមុខសម្រាប់ទិវាមួយម៉ោងសម្រាប់ភពផែនដីឆ្នាំ ២០១៤ ១១

**ចំណូល និងចំណាយរបស់អង្គការ WWF ប្រចាំប្រទេសកម្ពុជា** ១២



បានសរសេរ និងកែសម្រួលដោយកញ្ញា អាន់ញ៉ា នៀវីលល័រ (Anja Nieveler) និង លោក ភីលីព សែន (Philip Sen)/និទាន-រឿង-ពួកយើង (www.tell-our-story.com)
គំនិតផ្តួចផ្តើម និង រចនា ដោយ © កញ្ញា អាន់ញ៉ា នៀវីលល័រ និង លោក ភីលីព សែន /និទាន-រឿង-ពួកយើង ឆ្នាំ ២០១៤
រូបថតគម្របមុខ: © Nick Cox / WWF-Cambodia
បោះពុម្ពដោយ Three Q Colour / រាជធានីភ្នំពេញ, កម្ពុជា

បានបោះពុម្ពផ្សាយនៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៤ ដោយ អង្គការ WWF មូលនិធិសកលសម្រាប់ធនធានធម្មជាតិ (អតីតអង្គការមូលនិធិសត្វព្រៃពិភពលោក (World Wildlife Fund) រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។


រាល់ការផលិតឡើងវិញរួមមានការផលិតទាំងស្រុង ឬផ្នែកណាមួយក៏ដោយ ត្រូវតែលើកឡើងពីចំណងជើង និង ស្នាដៃរបស់អ្នកបោះពុម្ពផ្សាយជាម្ចាស់កម្មសិទ្ធិ។
© អត្ថបទ អង្គការ WWF ឆ្នាំ ២០១៤
រក្សាសិទ្ធិគ្រប់យ៉ាង


អង្គការ WWF គឺជាអង្គការឯករាជ្យដែលមានបទពិសោធន៍ក្នុងការអភិរក្សមួយធំជាងគេក្នុងចំណោមអង្គការធំៗដទៃទៀតនៅលើពិភពលោកដោយមានអ្នកឧបត្ថម្ភចំនួនច្រើនជាង ៥ លាននាក់ និង មានបណ្តាញជាសកលប្រមាណច្រើនជាង ១០០ ប្រទេសដ៏សកម្មមួយ។ បេសកកម្មរបស់អង្គការ WWF គឺដើម្បីបញ្ឈប់ការសឹករិចរិលបំផ្លិចបំផ្លាញបរិស្ថានធម្មជាតិរបស់ភពផែនដី និង ដើម្បីកសាងអនាគតមួយដែលមនុស្សអាចរស់នៅបានដោយភាពសុខដុមរម្យនាជាមួយនឹងធម្មជាតិតាមរយៈ៖ ការអភិរក្សជីវចម្រុះរបស់ពិភពលោក ការធានាថាមានការប្រើប្រាស់ធនធានធម្មជាតិកកើតឡើងវិញឲ្យមាននិរន្តភាព និង ធ្វើការផ្សព្វផ្សាយអំពីការកាត់បន្ថយការបំពុល និង ការប្រើប្រាស់កាកសំណល់ឡើងវិញ។

# ដៃគូ អភិរក្ស

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ដៃគូទាំងអស់ចំពោះការចូលរួមក្នុងការងារអភិរក្ស

Provincial Departments of the Environment (Mondulkiri, Kratie, Steung Treng)

Provincial Governor's Offices (Mondulkiri, Kratie and Steung Treng)

RECOFTC

Provincial Departments of Land Management, Urban Planning and Construction (Mondulkiri, Kratie, Steung Treng)

WWF-USA

Cambodian Federation for Bee Conservation and Community-Based Wild Honey Enterprises (CBHE)

Cambodia National Mekong Committee

Cambodia NTFP Working Group

Ministry of the Environment

Royal University of Phnom Penh

World Fish

Provincial Departments of Public Works and Transportation

Northeastern Rural Development (NRD)

Ministry of Agriculture, Fisheries and Forestry

Flora and Fauna International (FFI)

DANIDA

Smithsonian Conservation Biology Institute

Asian Development Bank (ADB)

Individual Donors

Ministry of Environment General Department of Administration of Nature Conservation and Protection

Save Cambodia's Wildlife (SCW)

WWF-Germany

University of Oxford - Wildlife Conservation Research Unit

Mondulkiri Wild Honey Network

Mondulkiri NGO Network

Rivers Coalition Cambodia

Cambodia Volunteers for Society (CVS)

October Hill Foundation

Provincial Departments of Commerce

Mondulkiri Forest Venture

Provincial Departments of Tourism (Mondulkiri, Kratie, Steung Treng)

Wildlife Conservation Society (WCS)

Culture and Environment Preservation Association (CEPA)

Royal University of Agriculture, Cambodia

Wetlands Alliance Project

Oxfam

ELIE - Elephant Valley Project

CEDAC

WWF-Denmark

Rattan Association of Cambodia

Non-timber Forest Products Exchange Programme (NFTP-EP)

Provincial and Military Police

3S Rivers Protection Network (3SPN)

General Department of Administration of Nature Conservation and Protection

WWF-Sweden

WWF-UK

United Nations Development Programme (UNDP)

Fisheries Action Coalition Team (FACT)

Cambodian Rural Development Team (CRDT)

Youth Resource Development Program (YRDP)

Phnom Tamao Zoological Park & Wildlife Rescue Center

IUCN

Community Economic Development (CED)

European Union

NGO Forum on Cambodia

BMZ

Birdlife International

Winrock

Wildlife Alliance

SIDA

My Village

Conservation International

HSBC

WWF-Switzerland

Nomad RSI

USAID

Association of Buddhists for the Environment (ABE)

Swiss Development Cooperation (SDC)

# សារលិខិតពីនាយកអង្គការ WWF ប្រចាំប្រទេសកម្ពុជា

> “ បេសកកម្មរបស់យើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានសារៈសំខាន់ខ្លាំងណាស់ ដូច្នេះគោលដៅយើងត្រូវតែមានសេចក្តីប្រាថ្នាធំធេង ។

យើងត្រូវតែបញ្ឈប់នូវការបំផ្លិចបំផ្លាញធនធានធម្មជាតិ និងជីវចម្រុះដ៏សម្បូរណ៍បែបរបស់ប្រទេសយើង ហើយកសាងអនាគតមួយដែលប្រជាជនកម្ពុជាយើងអាចរស់នៅបានដោយសុខដុមរម្យនាជាមួយនឹងធម្មជាតិ ។

ដើម្បីសម្រេចឲ្យបាននូវបេសកកម្មនេះ យើងចាំបាច់ត្រូវពុះពារគ្រប់ឧបសគ្គក្នុងគោលបំណងបង្កើតឲ្យមានតុល្យភាពរវាងការអភិរក្ស និងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងបង្កើតឲ្យមាននូវនិរន្តរភាពនៃការបំពេញការងារអភិរក្សនៅក្នុងប្រទេសកម្ពុជាយើង។ សកម្មភាពអភិរក្សរបស់យើងនៅតាមតំបន់ទេសភាពដែលជាទីតាំងគម្រោងគឺជាកិច្ចការបន្ទាន់ដែលយើងត្រូវបំពេញឲ្យបានញឹកញាប់ ប៉ុន្តែលទ្ធផលរំពឹងទុកចុងក្រោយគឺត្រូវលើកទឹកចិត្តឲ្យមានការផ្លាស់ប្តូរសម្រាប់រយៈពេលយូរអង្វែង ផ្តល់អំណាចដល់សហគមន៍តាមរយៈការចូលរួមយ៉ាងសកម្ម និងផ្តល់ភាពជាម្ចាស់ក្នុងកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិរបស់ប្រទេសកម្ពុជាយើង។

តាមរយៈរបាយការណ៍ប្រចាំឆ្នាំ ២០១៣-២០១៤នេះ យើងសូមចែករំលែកជាមួយឯកឧត្តម អស់លោក លោកស្រីនូវការយកចិត្តទុកដាក់របស់យើងលើការងារអភិរក្សបញ្ហាប្រឈម និងសមិទ្ធផលនានាអំពីលទ្ធផលចម្បងៗ បានមកពីការងារអភិរក្សតាមរ យៈការអនុវត្តការងារបច្ចេកទេសវិទ្យាសាស្ត្រ ការផ្តល់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋាន ការជម្រុញឲ្យមានការសម្រេចចិត្តលើគោលនយោបាយពាក់ព័ន្ធ និងតាមរយៈការពង្រឹងភាពជាដៃគូជាមួយដៃគូអាជីវកម្ម អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល។

អ្នកវិទ្យាសាស្ត្ររបស់យើងពិនិត្យឃើញថា កូនសត្វផ្សោតចំនួន ៦ ក្បាលកំពុងបន្តរស់រានមានជីវិតនៅតាមដងទន្លេមេគង្គដែលជាដែនជម្រករបស់វា ហើយអត្រាស្លាប់ជាមធ្យមប្រចាំឆ្នាំរបស់សត្វផ្សោតទន្លេមេគង្គដែលជា ប្រភេទសត្វកំពុងទទួលរងគ្រោះឈានទៅរកភាពផុតពូជនោះមានការធ្លាក់ចុះគួរឲ្យកត់សម្គាល់។ បច្ចុប្បន្ននេះ តំបន់អភិរក្សនិងគ្រប់គ្រងជីវចម្រុះជលផលដែលមានតែមួយគ្មានពីរ ស្ថិតនៅក្នុងតំបន់ទេសភាពខេត្តក្រចេះ ស្ទឹងត្រែង និងស៊ីផានដុនដែលមានសារៈសំខាន់ផ្នែកអេកូឡូស៊ី និងសេដ្ឋកិច្ចនោះត្រូវបានកំណត់ជាតំបន់ការពារពិសេសដោយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាយើង។ ការត្រួតពិនិត្យយ៉ាងល្អិតល្អន់នៅក្នុងព្រៃល្បោះនៃតំបន់ទេសភាពខ្ពង់រាបភាគខាងកើតបង្ហាញថា បើទោះជាសម្ពាធទៅលើតំបន់ទេសភាពនេះមានការកើនឡើងក៏ដោយ ក៏ចំនួនសត្វដែលជាចំណីរបស់សត្វខ្លានៅមានស្ថេរភាពនៅឡើយ។ លើសពីនេះទៀត សហគមន៍មូលដ្ឋានមានអំណាចពេញលេញក្នុងការការពារប្រភពធនធានធម្មជាតិរបស់ខ្លួនតាមរយៈឱកាសទាញយកប្រាក់ចំនូល និងការកសាងសមត្ថភាពរបស់ក្រុមល្បាតនៃសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ។

យើងនៅមានកិច្ចការជាច្រើនដែលត្រូវបំពេញដើម្បីទប់ស្កាត់ការបំផ្លិចបំផ្លាញទីកន្លែងដែលមានតម្លៃជីវចម្រុះខ្ពស់ ប្រភេទសត្វដែលកំពុងរងគ្រោះ និងទីជម្រកសត្វព្រៃ ក៏ដូចជាទីជម្រករបស់មនុស្សយើងផងដែរ។ ប្រសិនបើយើងមិនបានចាប់ផ្តើមបំពេញការងារការពារ និងអភិរក្សពីពេលនោះទេនោះ ព្រៃឈើដ៏មានតម្លៃ និងជីវចម្រុះទឹកសាបដ៏សម្បូរណ៍បែបនៃមហាតំបន់ទន្លេមេគង្គ អាចនឹងបាត់បង់នាពេលអនាគតដ៏ខ្លីខាងមុខនេះ។

ដើម្បីជំនះបញ្ហាទាំងនេះឲ្យបានជោគជ័យ យើងត្រូវតែបន្តពង្រឹងភាពជាដៃគូរបស់យើង។ ខ្ញុំសូមឆ្លៀតយកឱកាសនេះដើម្បីបង្ហាញពីការដឹងគុណដ៏ជ្រាលជ្រៅរបស់ខ្ញុំចំពោះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល ដៃគូស្រាវជ្រាវ និងអាជីវកម្ម និងម្ចាស់ជំនួយដែលមានសណ្តានចិត្តដ៏សប្បុរសដែលជួយធ្វើឲ្យការងាររបស់យើងអាចដំណើរការទៅបាន។ យើងទន្ទឹងរង់ចាំទទួលយកជានិច្ចនូវរាល់ការបន្តគាំទ្រដ៏សកម្មរបស់លោកអ្នក។ ជាងនេះទៅទៀត ខ្ញុំសូមថ្លែងអំណរគុណដល់ក្រុមការងារអង្គការ WWF-កម្ពុជាទាំងអស់។ ការប្រាថ្នាចង់បាននូវសមិទ្ធិផល និងលទ្ធផលពីការងារអភិរក្ស និងការប្តេជ្ញាចិត្តរបស់ពួកគាត់ គឺជាការលើកទឹកចិត្តដល់ខ្លួនខ្ញុំផ្ទាល់ជារៀងរាល់ថ្ងៃ។

**នាយកប្រចាំប្រទេស**
**ឈិត សំអាត**



© អង្គការ WWF-កម្ពុជា

*WWF-Cambodia Staff Retreat, Sihanoukville, May 2014.*



## យុទ្ធសាស្ត្រអភិរក្សរបស់ អង្គការ WWF ប្រចាំប្រទេសកម្ពុជា

កម្មវិធីអភិរក្សរបស់អង្គការ WWF ប្រចាំប្រទេសកម្ពុជាបានចាប់ផ្តើមសកម្មភាពរបស់ខ្លួនក្នុងរយៈពេលជាង ១៥ ឆ្នាំកន្លងមកហើយ។ កម្មវិធីនេះផ្តោតទៅលើការអនុវត្តច្បាប់ និងគោលនយោបាយថ្នាក់ជាតិ និងការបំពេញសកម្មភាពការងារនៅតាមទីតាំងគម្រោងនៅក្នុងតំបន់ទេសភាពចំនួនពីរ រួមមាន៖ តំបន់ទេសភាពខ្ពង់រាបភាគខាងកើត (EPL) ដែលសម្បូរណ៍ទៅដោយបណ្តុំព្រៃល្បោះ និង តំបន់ទេសភាពស៊ីផានដុន-ស្ទឹងត្រែង-ក្រចេះ (SSK) ដែលលាតសន្ធឹងតាមដងទន្លេមេគង្គ។ កម្មវិធីនេះត្រូវបានបង្កើតឡើងដោយផ្អែកលើការអនុវត្តយុទ្ធសាស្ត្រចំនួនបួនដូចខាងក្រោម៖

(១) ការធានានូវការបង្កើតឲ្យមានជម្រើសរបរចិញ្ចឹមជីវិតផ្សេងៗ និងការអភិរក្សតំបន់ទេសភាពប្រកបដោយនិរន្តរភាព
(២) ហេដ្ឋារចនាសម្ព័ន្ធទំនប់វារីអគ្គីសនីទឹកសាបដោយនិរន្តរភាព
(៣) ការគ្រប់គ្រងតំបន់ការពារ ការពង្រឹងលើការអនុវត្តច្បាប់ ការស្រាវជ្រាវ និង ការអភិរក្ស
(៤) ការផ្តល់ហិរញ្ញប្បទាន និង សេដ្ឋកិច្ចបៃតងប្រកបដោយនិរន្តរភាព ។

## ប្រភេទសត្វ ចំនួន ២២៨ លើសពីការរំពឹងទុក

ការអង្កេតចំណីសត្វខ្លាបានរកឃើញថាប្រភេទសត្វមានច្រើនលើសពីការរំពឹងទុកដែលមានចំនួនដល់ទៅ ២២៨ ប្រភេទ រួមមានទាំងសត្វទន្សោងដែលរងគ្រោះជិតផុតពូជជាសកលផងដែរ។

## ការស្តារយកចំនួនសត្វខ្លាត្រឡប់មកវិញ

បច្ចុប្បន្ននេះ រដ្ឋបាលព្រៃឈើកំពុងរៀបចំបង្កើតផែនការគ្រប់គ្រងព្រៃការពារមណ្ឌលគិរី ក្នុងនោះកម្មវិធីស្តារឡើងវិញនូវចំនួនសត្វខ្លាត្រូវបានដាក់បញ្ចូល ហើយគឺរំពឹងថាសត្វខ្លានឹងមានវត្តមានជាថ្មីនៅក្នុងតំបន់ទេសភាពខ្ពង់រាបភាគខាងកើត (EPL) នៅក្នុងអំឡុងឆ្នាំ ២០២២។

# ការការពារបណ្តុំព្រៃល្បោះរបស់ប្រទេសកម្ពុជា

កម្មវិធីតំបន់ទេសភាពខ្ពង់រាបភាគខាងកើត (EPL) បានការពារបណ្តុំព្រៃល្បោះដ៏ធំបំផុតមួយដែលមិនទាន់ ទទួលរងនូវការបំផ្លិចបំផ្លាញនៅឡើយ និងដែលនៅសេសសល់នៅក្នុងតំបន់ឥណ្ឌូចិនយើងនេះតាំងពីឆ្នាំ ២០០១ មកម្ល៉េះ។ កម្មវិធីនេះផ្តោតទៅលើការការពារប្រព័ន្ធអេកូឡូស៊ី និងជីវចម្រុះនៃតំបន់ទេសភាព ភាពបន្សាំនៃការប្រែប្រួលអាកាសធាតុ ការពង្រឹងលើការអនុវត្តច្បាប់ ការចូលរួមរបស់សហគមន៍មូលដ្ឋាន និងការស្រាវជ្រាវជីវសាស្ត្រ។ អង្គការ WWF កំពុងធ្វើការជាដៃគូជាមួយរដ្ឋាភិបាលលើការគ្រប់គ្រងព្រៃការពារមណ្ឌលគិរី និងតំបន់ដែនជម្រកសត្វព្រៃភ្នំព្រិចមានទំហំសរុបប្រមាណ ១៦,000km² និងឆ្លើយតបទៅនឹងការគំរាមកំហែងពីការបំលែងដីព្រៃ រហូតដល់ការជួញដូរសត្វព្រៃខុសច្បាប់ ការទន្ទ្រានយកដីធ្លី និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជាដើម។

អង្គការ WWF បានរៀបចំបង្កើតឲ្យមានការផ្តួចផ្តើមលើការ ងា រអភិរក្សដោយមានការលើកទឹកចិត្ត ក្នុងកិច្ចសហការជាមួយសហភាពអឺរ៉ុប EU និងភ្នាក់ងារអភិវឌ្ឍអន្តរជាតិអាមេរិក USAID ដោយផ្តល់ការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងគោលបំណងគ្រប់គ្រងតំបន់ការពារឲ្យកា ន់តែប្រសើរឡើងកែលំអរមុខរបរ ចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានតាមរយៈការបង្កើតសហគ្រាសដោយមានការចូលរួ ម របស់សហគមន៍ និងតាមរយៈការទាក់ទាញវិនិយោគទុនរបស់វិស័យឯកជនប្រកបដោយនិរន្តរភាព ក្នុងគោលបំណងផ្តល់ហិរញ្ញ ប្បទានដល់ការគ្រប់គ្រងតំបន់ការពារ។ បណ្តាអាជីវកម្មខ្នាតតូចដែលដំណើរការដោយសហគមន៍មូលដ្ឋានមានរាប់បញ្ចូលនូវការយកជ័រទឹក និងការថែទាំឃ្មុំព្រៃ ហើយនឹងត្រូវបានគាំទ្រតាមរយៈយន្តការវិនិយោគ។ អង្គការ WWF បានចូលរួម និងជួយកសាងសមត្ថភាពស្ថាប័នរដ្ឋាភិបាលថ្នាក់ខេត្តក្នុងគោលបំណងឲ្យស្ថាប័នទាំងនោះយល់ដឹងកាន់តែប្រសើរឡើងអំពីសេវាកម្មប្រព័ន្ធអេកូឡូស៊ីដែលមានវត្តមាននៅក្នុងខេត្តមណ្ឌលគិរី តាមរយៈការរៀបចំបង្កើតផែនទីអំពីសេវាកម្មប្រព័ន្ធអេកូឡូស៊ីទាំងនោះ និងការវាយតម្លៃសេដ្ឋកិច្ច។

អង្គការ WWF បានចាត់វិធានការជាបន្តបន្ទាប់ដើម្បីជំរុញឲ្យមានអេកូទេសចរណ៍ ហើយបាននឹងកំពុងគាំទ្រលើការរៀបចំបង្កើតផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍ទេសចរណ៍របស់ខេត្តមណ្ឌលគិរី ក្នុងគោលបំណងបង្កើនភ្ញៀវទេសចរអោយបានកើនឡើងច្រើនដល់ទៅដល់ ៣00,000 នាក់នៅត្រឹមឆ្នាំ ២០១៨ ខាងមុខនេះ។



## ប្រជាជនក្នុងចំនួន ជាង ១0,000 នាក់

ប្រជាជនទាំងនោះបានទទួលអត្ថប្រយោជន៍ពីការកើនឡើងនៃសេដ្ឋកិច្ច ដែលបានមកពីការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងឱកាសក្នុងការអភិរក្ស។

## នៅតាមព្រំដែន

ប្រទេសកម្ពុជា និង ប្រទេសវៀតណាមបានឯកភាពឲ្យមានកិច្ចសហប្រតិបត្តិនៃការអភិរក្សឆ្លងព្រំដែនរវាងតំបន់ទេសភាពខ្ពង់រាបភាគខាងកើតនៅក្នុងប្រទេសកម្ពុជា និងព្រំដែនសួនឧទ្យានជាតិយុគដុននៃប្រទេសវៀតណាម។

តំបន់ទេសភាពខ្ពង់រាបភាគខាងកើតមើលពីលើ នៃខេត្តមណ្ឌលគិរី ប្រទេសកម្ពុជា

© Nick Cox/ WWF-Cambodia

# សកម្មភាព
# ក្នុងឆ្នាំ ២០១៣ - ២០១៤

យើងបានបំពេញរួចរាល់នូវការងារជាច្រើនក្នុងអំឡុងពេលពីរឆ្នាំកន្លងមកនេះ។ ខណៈពេលដែលកំពុងមមាញឹកក្នុងការកំណត់គោលបំណងរបស់កម្មវិធី និងកំពុងបំពេញការងារក្នុងគោលបំណងសម្រេចឲ្យបាននូវលទ្ធផលរំពឹងទុកនោះ បញ្ហាប្រឈមថ្មីជាច្រើនបានកើតមានឡើងនៅក្នុងតំបន់ទេសភាពដែលតម្រូវឲ្យយើងជំនះឲ្យបាន។ យើងបានឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះដោយភាពជឿជាក់ ប្រើដំណោះស្រាយតាមបែបវិទ្យាសាស្ត្រត្រឹមត្រូវ និងដោយទទួលបាននូវការឧបត្ថម្ភគាំទ្រយ៉ាងច្រើនពីដៃគូរបស់យើង។ យើងអបអរសាទរចំពោះភាពរីកចម្រើននៃការបំពេញសកម្មភាពអភិរក្ស និងបណ្ដាសមិទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

## ការគាំទ្រដល់អ្នកការពារធនធានធម្មជាតិ...


© Asnarith Tep/ WWF-Cambodia

ឆ្មាំទន្លេចេញដើរល្បាតនៅភូមិកែងប្រាសាទ ស្រុកសម្បូរណ៍ ខេត្តក្រចេះ

អង្គការ WWF បានជ្រើសរើសបុគ្គលិកថ្មីចំនួន ១៣ នាក់ដែលតំណាងឲ្យរដ្ឋាភិបាល និងសហគមន៍មូលដ្ឋានដើម្បីជួយដល់សកម្មភាពពង្រឹងលើអនុវត្តច្បាប់ការពារសត្វព្រៃ ទីជម្រកសត្វព្រៃ និងប្រភពធនធានធម្មជាតិនៅក្នុងតំបន់ព្រៃការពារមណ្ឌលគិរី។ ឆ្មាំទន្លេសរុបចំនួន ៦៧ រូបកំពុងប្រចាំការនៅតាមដងទន្លេមេគង្គដែលម្នាក់ៗទទួលបានការហ្វឹកហ្វឺនលើសពី២៥ម៉ោង និងសម្ភារៈចាំបាច់មួយចំនួនទៀតដូចជា៖ អាវពោង និងឧបករណ៍កំណត់ទីតាំងភូមិសាស្ត្រ GPS ។ ការគាំទ្រ និងជំនួយឧបត្ថម្ភទាំងនេះអាចជួយពួកគេដើរល្បាត និង ពង្រឹងលើការអនុវត្តច្បាប់ការពារជីវចម្រុះ និង ធនធានជលផលនៅក្នុងទន្លេមេគង្គ។




## ការរីកលូតលាស់ឧស្សាហកម្មផ្ដៅប្រកបដោយនិរន្តរភាព...

ដោយសហការជាមួយសមាគមផ្ដៅកម្ពុជាដែលជាដៃគូរបស់ខ្លួន អង្គការ WWF ជួយបណ្ដុះបណ្ដាលអ្នកភូមិសរុបចំនួន ៦០៩ នាក់ និងសហគ្រាសផ្ដៅចំនួន ៧ ហើយពង្រីកផ្ទៃដីព្រៃបន្ថែមចំនួន ១៧៨ ហិចតា ដោយបានដាំកូនផ្ដៅថ្មីចំនួន ១៣៥,២៥០ដើមក្នុងរយៈពេលបីឆ្នាំ។នាពេលបច្ចុប្បន្ននេះ ព្រៃធម្មជាតិប្រមាណជាង ៨,៣០០ ហិកតា ដែលស្ថិតនៅក្នុងខេត្តចំនួនប្រាំកំពុងស្ថិតក្រោមការគ្រប់គ្រងប្រកបដោយនិរន្តរភាព និងមានការគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា។


© Khem Chhor Vida / WWF-Cambodia

ផលិតផលផ្ដៅបានដាក់តាំងជាសាធារណៈនៅក្នុងសិក្ខាសិលាស្ដីពីការបិទដំណាក់កាលទី ៣ នៃគម្រោងផ្ដៅ ស្ថិតនៅរាជធានីភ្នំពេញ

To find out more, visit cambodia.panda.org

# ការកំណត់លើការការពារព្រៃលិចទឹកនៃទន្លេមេគង្គ...

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញជាផ្លូវការនូវប្រកាសស្តីពីការកំណត់ទន្លេមេគង្គក្នុងចម្ងាយ ៥៦km ពីទីរួមខេត្តក្រចេះ ដល់ទីរួមខេត្តស្ទឹងត្រែងជា «តំបន់គ្រប់គ្រង និងអភិរក្សជីវចម្រុះ និងប្រភពធនធានជលផល»។ ដោយយល់ច្បាស់ពីធនធានជីវចម្រុះដ៏មានតម្លៃដែលនៅសេសសល់ ការទទួលស្គាល់ជាផ្លូវការពីតម្រូវចាំបាច់ក្នុងការការពារតំបន់ព្រៃលិចទឹកទន្លេមេគង្គរបស់ប្រទេសកម្ពុជា ផ្តល់ឲ្យយើងទាំងអស់គ្នានូវឱកាសជួយសង្គ្រោះសត្វ និងរុក្ខជាតិជាច្រើនប្រភេទដែលមានតម្លៃជាលក្ខណៈសកលដូចជា៖  សត្វត្រយ៉ងចំកំកសដែលកំពុងរងគ្រោះថ្នាក់អាចឈានទៅរកភាពផុតពូជ និង រុក្ខជាតិមួយប្រភេទស្ថិតក្នុងអំបូរត្រាវ (amorphallus SP. ) ដែលជាកំណត់ត្រាថ្មីសម្រាប់វិទ្យាសាស្រ្ត ។




## ការលើកកម្ពស់សេដ្ឋកិច្ចបៃតង...

ការលើកកម្ពស់សេដ្ឋកិច្ចបៃតងគឺជាផ្នែកមួយដ៏សំខាន់នៃមាគ៌ាបង្ហាញផ្លូវរបស់ប្រទេសកម្ពុជាក្នុងការសម្រេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព។ អង្គការ WWF កំពុងរៀបចំបង្កើតយុទ្ធសាស្រ្តគ្រប់គ្រង និងវាយតម្លៃឲ្យបានសមស្របលើមូលធនធម្មជាតិក្នុងប្រទេសកម្ពុជា ដោយមានគោលបំណង ប្រមូលផលិតផល និងអនុផលព្រៃឈើ ផលិតផលកសិកម្មជលផល និងថាមពលអគ្គិសនីប្រកបដោយនិរន្តរភាព ដើម្បីធានាឲ្យមាននូវសមធម៌សង្គម និងសិទ្ធពេញលេញរបស់ប្រជាជនកម្ពុជាគ្រប់រូបក្នុងការទាញយកធនធានធម្មជាតិ។ យើងទាំងអស់គ្នាក្នុងកិច្ចសហការជាមួយអង្គការអភិរក្សអន្តរជាតិ និង អង្គការហ្វ៍រណា  & ហ្វ្ល័រ៉ាអន្តរជាតិ (Flora & Fauna International) អង្គការ WWF កំពុងបំពេញការងារលើការកសាងសមត្ថភាព។ នៅក្នុងឆ្នាំ ២០១៣ មាគ៌ាបង្ហាញផ្លូវត្រូវបានចាត់ទុកជាយុទ្ធសាស្រ្តជាតិសម្រាប់លើកទឹកចិត្តឲ្យមានកំណែទម្រង់ និងការរៀបចំបង្កើតគោលនយោបាយសំខាន់ៗមួយចំនួន។

## ការកែលំអររបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន...

ការកែលំអររបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋានតាមរយៈការអភិរក្សគឺជាអាទិភាពចម្បងរបស់អង្គការ WWF ។ ហេហ្វីឡឹម (Hefalump) ដែលជាហាងកាហ្វេទេសចរណ៍ធម្មជាតិដំបូងទីមួយ និងហាងលក់ផលិតផលទឹកឃ្មុំដំបូងទីមួយត្រូវបានបង្កើតឡើងក្នុងខេត្តមណ្ឌលគិរីដោយអង្គការ WWF ក្នុងកិច្ចសហការជាមួយដៃគូរបស់ខ្លួនគាំទ្រអេកូទេសចរណ៍ និងផលិតផលក្នុងស្រុក។ តាមរយៈដៃគូក្នុងស្រុក និងសហគមន៍មូលដ្ឋាន អង្គការ WWF បានជម្រុញឲ្យមានការទាញយកផលិតផលអនុផលព្រៃឈើប្រកបដោយនិរន្តរភាព និងផ្តល់អំណាចដល់សហគមន៍ធ្វើជាម្ចាស់ក្នុងការការពារធនធានធម្មជាតិរបស់ពួកគេដោយផ្តល់នូវវគ្គបណ្តុះបណ្តាល និងបង្កើតឲ្យមានទំនាក់ទំនងទីផ្សារជាដើម។



© Song Chhapon Mina / WWF-Cambodia

បណ្តាអ្នកជិះកង់ទាំងអស់បានចូលរួមក្នុងកម្មវិធីជិះកង់កំសាន្តជុំវិញទីរួមខេត្តសែនមនោរម្យ នៃខេត្តមណ្ឌលគីរី ដែលជាផ្នែកមួយផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ទេសចរខេត្តមណ្ឌលគីរីសម្រាប់ឆ្នាំ ២០១៤ ដល់ ២០១៨

facebook.com/wwfcambodia

www.youtube.com/wwfcambodia



## តើអ្វីទៅជាតំបន់ទេសភាព ?

តំបន់ទេសភាពគឺជាតំបន់ព័ទ្ធជុំវិញដោយបណ្តុំដីដោយរាប់បញ្ចូលទាំងដីដាំដុះ និង ដីព្រៃដែលគ្របដណ្តប់លើទីតាំងភូមិសាស្រ្តធំទូលាយដែលទ្រង់ទ្រាយរបស់វាប្រែប្រួលដោយអន្តរអំពើរបស់មនុស្សគ្រប់ពេលវេលា (អង្គការ IUCN ឆ្នាំ ២០០៥)។ យើងប្រើប្រាស់និយមន័យនេះជាមូលដ្ឋានក្នុងការបង្កើតអភិក្រមក្នុងការគ្រប់គ្រង និងបង្កើតសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងតួនាទីចម្រុះតាមបែបសមាហរណកម្មប្រកបដោយនិរន្តរភាព។

# ប្រាំមួយ

កូនសត្វផ្សោតនៅក្នុងទន្លេមេគង្គដែលកំពុងត្រូវបានអង្កេតក្នុងពេលដែលអត្រាស្លាប់ជាមធ្យមប្រចាំឆ្នាំបានធ្លាក់ចុះពីចំនួន ១១ ក្បាល មកត្រឹម៥ក្បាល នោះបង្ហាញឲ្យឃើញពីសញ្ញាណនៃក្តីសង្ឃឹមក្នុងការសង្រ្គោះប្រភេទសត្វដែលកំពុងរងគ្រោះអាចឈានទៅរកភាពផុតពូជនេះមានជីវិតឡើងវិញ។

# តំបន់រ៉ាមសារ ខេត្តស្ទឹងត្រែង

ផែនការគ្រប់គ្រងតំបន់នេះត្រូវបានអនុម័តយល់ព្រមដោយរដ្ឋបាលខេត្តស្ទឹងត្រែង និងកំពុងរង់ចាំការអនុម័តពីថ្នាក់ជាតិ។

# កិច្ចការពារតំបន់ទន្លេមេគង្គ

តំបន់ទន្លេមេគង្គដែលហូរកាត់ប្រទេសចំនួនប្រាំគឺជាទីជម្រកសម្រាប់ការរស់នៅរបស់សត្វសំខាន់ៗជាច្រើនប្រភេទ និងជាកន្លែងបន្តពូជដ៏សំខាន់បំផុតក្នុងពិភពលោកយើងនេះសម្រាប់វារីសត្វទឹកសាប ហើយជាកន្លែងដែលប្រជាជនប្រមាណជាង ៦០លាននាក់កំពុងពឹងអាស្រ័យសម្រាប់របរចិញ្ចឹមជីវិត និងប្រភពស្បៀង។ ទន្លេមេគង្គដែលជាប់លំដាប់ទីពីរបន្ទាប់ពីទន្លេអាម៉ាស៊ូន (Amazon) ជាទន្លេដែលសម្បូរណ៍ទៅដោយមច្ឆាគ្រប់ប្រភេទ និងជីវចម្រុះដ៏សម្បូរណ៍បែប ហើយត្រូវបានចាត់ទុកជាតំបន់មួយក្នុងចំណោមតំបន់អេកូទាំង ២០០ កន្លែងរបស់អង្គការ WWF នៅក្នុងពិភពលោកយើងនេះ។

តំបន់ទេសភាពនៃទន្លេស៊ីផានដន-ស្ទឹងត្រែង-ក្រចេះ (SSK) បានក្លាយជាតំបន់អាទិភាពរបស់អង្គការ WWF នៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ២០០៦ មកម្ល៉េះ។ ការការពារតំបន់នេះផ្តោតសំខាន់ទៅលើការការពារប្រភេទសត្វដែលកំពុងរងគ្រោះជិតផុតពូជ និងទីជម្រករបស់វាតាមរយៈ ការសិក្សាស្រាវជ្រាវ ការចូលរួមរបស់សហគមន៍មូលដ្ឋាន ការពង្រឹងលើការអនុវត្តច្បាប់ និងការជួយរៀបចំគោលនយោបាយរបស់រាជរដ្ឋាភិបាល។ តាមរយៈការចូលរួមយ៉ាងជិតស្និទ្ធជាមួយសហគមន៍មូលដ្ឋាន រដ្ឋាភិបាល ថ្នាក់ខេត្ត និងថ្នាក់ជាតិ នោះអង្គការ WWF ធ្វើការបញ្ជ្រាបចូលនូវការគ្រប់គ្រងលើការអភិរក្សទៅក្នុងផែនការអភិវឌ្ឍន៍ដោយធានាបាននូវនិរន្តរភាពនៃរបរចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន ការការពារជីវចម្រុះ និងការប្រើប្រាស់ដីធ្លី។

ការខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នានាំមកនូវការប្តេជ្ញាចិត្តដ៏ខ្លាំងក្លាបន្ថែមទៀត និងការអបអរសាទរលើលទ្ធផលដ៏ល្អជាទីគាប់ចិត្ត។ តំបន់ព្រៃលិចទឹកទន្លេមេគង្គត្រូវបានកំណត់នាពេលកន្លងមកថ្មីៗនេះជាតំបន់គ្រប់គ្រង និងការការពារពិសេសហើយផែនការគ្រប់គ្រងតំបន់រ៉ាំសារខេត្ត ស្ទឹងត្រែងនឹងទទួលបានការអនុម័តនាពេលដ៏ខ្លីខាងមុខ។ អង្គការ WWF បន្តគាំទ្រដល់រដ្ឋាភិបាលក្នុងការការពារតំបន់ទេសភាពតាមរយៈការបណ្តុះ បណ្តាលឆ្មាំទន្លេ និងការផ្តល់នូវសម្ភារៈមូលដ្ឋាន ជាមួយគ្នានេះដែរអង្គការ WWF ផ្តល់អំណាចដល់ប្រជាជនប្រមាណជាង ២,៥០០ នាក់ដែលរស់នៅក្នុងនិងជុំវិញតំបន់ការពារ ទទួលបានសិទ្ធិដើម្បីលើកកម្ពស់ការយល់ដឹងអំពីតម្លៃធនធានធម្មជាតិប្រកបដោយនិរន្តរភាព កែលំអររបរចិញ្ចឹមជីវិតរបស់ពួកគេ និងជួយបង្កើតក្រុមសហគមន៍ព្រៃឈើ និងនេសាទដែលសហគមន៍មូលដ្ឋានទាំងនោះចូលរួមការពារប្រភពធនធានធម្មជាតិរបស់ខ្លួនផ្ទាល់។



## ភូមិចំនួន ២៦
## សាលារៀនចំនួន ១៣
## ទីវត្តអារាមចំនួន ១១

ប្រជាជនក្នុងភូមិ សាលារៀន និងវត្តអារាមទាំងនោះសុទ្ធតែបានទទួលការបណ្តុះបណ្តាលអំពីកិច្ចការសត្វផ្សោត និងសំបុករបស់សត្វស្លាបដែលកំពុងរងគ្រោះថ្នាក់ជិតផុតពូជ។ ប្រជាជនប្រមាណ ៨៤៩នាក់ បានចូលរួមសិក្ខាសាលាអំពីអេកូទេសចរណ៍ និង ផលប៉ះពាល់នៃទំនប់វារីអគ្គិសនី ដន សាហុង។

## មងនេសាទខុសច្បាប់ជាង ៧០,០០០+ ម៉ែត្រ

មងនេសាទខុសច្បាប់ទាំងនោះត្រូវបានរឹបអូសពីតំបន់ស្នូលសម្រាប់ការពារសត្វផ្សោត។ យុទ្ធសាស្រ្តអនុវត្តច្បាប់ជាច្រើនត្រឹមត្រូវបានពិនិត្យ និងបានអនុម័ត។

សត្វផ្សោតអ៊ីរ៉ាវ៉ាឌីទន្លេមេគង្គកំពុងហែលចុះឡើងនៅក្នុងអាងកាំពីនៃខេត្តក្រចេះ

© Gerard Ryan / WWF-Cambodia

# ការអភិរក្សសត្វ
# និងការចូលរួមរបស់ ប្រជាជន

«មានតែតាមរយៈការធ្វើការរួមគ្នាប៉ុណ្ណោះទើបអាចឲ្យយើងការពារបាននូវប្រភេទសត្វជិតពូជនៅក្នុងតំបន់ទេសភាពអាទិភាពទាំងពីរ ជាមួយគ្នានេះដែរយើងត្រូវលើកកម្ពស់របរពាណិជ្ជកម្មឲ្យមាននិរន្តរភាព»

© Foresty Administration & WWF-Cambodia



### ការស្តារចំនួនសត្វខ្លាឡើងវិញនៅក្នុងប្រទេសកម្ពុជា

កាលពី ៥០ ឆ្នាំកន្លងទៅនេះ តំបន់ទេសភាពខ្ពង់រាបភាគខាងកើតគឺជាទីជម្រករបស់សត្វខ្លារាប់ពាន់ក្បាល។ ប៉ុន្តែយើងមិនទទួលបានកំណត់ត្រាថ្មីណាមួយនៃវត្តមានរបស់សត្វខ្លាចាប់តាំងពីឆ្នាំ២០០៧មកម្ល៉េះ។ទោះជាយ៉ាងណាក៏ដោយ គុណភាពរបស់ទីជម្រកសត្វនេះបានធ្វើឱ្យតំបន់ទេសភាពខ្ពង់រាបភាគខាងកើតនៅតែជាតំបន់មួយក្នុងចំណោមតំបន់នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍សម្រាប់គម្រោងស្តារយកចំនួនសត្វខ្លាត្រឡប់មកវិញ។ ដើម្បីធានាឲ្យបានថាសត្វខ្លាមានទីជម្រកធំទូលាយ និងមានបរិមាណសត្វដែលជាអាហាររបស់ខ្លួនគ្រប់គ្រាន់ អង្គការ WWF-កម្ពុជាបានរៀបចំសិក្សាស្រាវជ្រាវអំពីវត្តមានរបស់ប្រភេទសត្វដែលជាចំនីអាហាររបស់សត្វខ្លា ហើយបានដាក់ជូនរាជរដ្ឋាភិបាលនូវរបាយការណ៍អំពី ការសិក្សាលើលទ្ធផលស្តារឡើងវិញនៃចំនួនសត្វខ្លានាពេលថ្មីៗនេះក្នុងគោលបំណងជំរុញនូវកិច្ចសហប្រតិបត្តិការលើកម្មវិធីនេះ។

សត្វខ្លាព្រៃមួយក្បាលដែលបានថតដោយម៉ាស៊ីនថតស្វ័យប្រវត្តិនៅក្នុងព្រៃការពារមណ្ឌលគីរីនាឆ្នាំ ២០០៥

**ឯកឧត្តម ឆេង គឹមស៊ុន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា និងជាប្រធានរដ្ឋបាលព្រៃឈើបានមានប្រសាសន៍ថា " ការឧបត្ថម្ភគាំទ្រពីសំណាក់អង្គការ WWF ពិតជាមានសារៈសំខាន់ក្នុងការកសាងសមត្ថភាពមន្ត្រីមូលដ្ឋានលើការត្រួតពិនិត្យ និងការពង្រឹងលើការអនុវត្តច្បាប់ទប់ស្កាត់ប្រកបដោយប្រសិទ្ធិភាពលើការកាប់បំផ្លាញព្រៃឈើនៅតំបន់ទេសភាពខ្ពង់រាបភាគខាងកើត"។

© Bjorn Svensson / WWF-Cambodia





**លោក អោ ចាន់នី** នាយកប្រតិបត្តិនៃអង្គការអភិវឌ្ឍន៍ជនបទកម្ពុជាបានមានប្រសាសន៍ថា "យើងសូមទទួលស្គាល់ អង្គការ WWF ជាដៃគូរបស់យើងក្នុងការអភិវឌ្ឍន៍គម្រោងរបរចិញ្ចឹមជីវិត និងអេកូទេសចរណ៍ ដែលគម្រោងនេះកំពុងជួយឲ្យប្រជាជនជាច្រើនគេចផុតពីភាពក្រីក្រ"។

**លោក សេង ប៊ុនរ៉ា** នាយកប្រចាំប្រទេសនៃអង្គការអភិរក្សអន្តរជាតិបានមានប្រសាសន៍ថា "អង្គការ WWF ជាដៃគូដ៏សំខាន់របស់អង្គការអភិរក្សអន្តរជាតិ ពិសេសគឺជាដៃគូក្នុងការជម្រុញឲ្យមានការសិក្សាពីតម្រូវការនៃការបង្កើតតំបន់ការពារ ពិនិត្យមើលពីកន្លែងការពារក្នុងប្រទេសកម្ពុជា និងជួយបង្កើតគោលនយោបាយអំពីការអភិវឌ្ឍន៍បៃតងដោយផ្អែកលើមូលដ្ឋាននៃព័ត៌មាន និងទិន្នន័យវិទ្យាសាស្ត្រ"។

## ទន្លេមេគង្គដ៏អាថ៌កំបាំង: បានរកឃើញប្រភេទសត្វថ្មីចំនួន ១៣ ប្រភេទ

បក្សីមួយប្រភេទគួរឲ្យភ្ញាក់ផ្អើលមានឈ្មោះថា ចាបតេតចតុមុខ (Cambodian Tailorbird) រស់នៅក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជាសត្វថ្លែនរើនសៃ (rainbow lizard) មកពីខេត្តរតនៈគិរី និងពស់ត្រី (Zorro-masked snake) គឺជាប្រភេទសត្វតែបីប៉ុណ្ណោះនៅក្នុងចំណោមប្រភេទសត្វចំនួន ១៣ ដែលទើបតែរកឃើញថ្មីៗនេះដោយអ្នកវិទ្យាសាស្ត្រ ក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០១២-២០១៣ ហើយក៏បានពិពណ៌នានៅក្នុងរបាយការណ៍ទន្លេមេគង្គដ៏អាថ៌កំបាំងថ្មីរបស់អង្គការ WWF ។



© Cambodian Tailorbird by James Eaton/ Birdtour Asia



**ឯកឧត្តមបណ្ឌិត ណៅ ធួក** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផលនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទបានមានប្រសាសន៍ថា "ប្រជាជនកម្ពុជារាប់លាននាក់ពឹងអាស្រ័យលើត្រីជាប្រភពចម្បងនៃប្រូតេអ៊ីន ហើយការពឹងអាស្រ័យនេះនឹងប៉ះពាល់លើជីវចម្រុះនៃទន្លេមេគង្គដោយមិនអាចបញ្ចៀសបាន។ ប៉ុន្តែយើងអាចកាត់បន្ថយរាល់ផលប៉ះពាល់ទាំងនោះបានដោយសហការជាមួយដៃគូរបស់យើងដូចជាអង្គការ WWF ជាដើម"។

**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានមានប្រសាសន៍ថា "យើងបូជាកម្លាំងកាយចិត្តដើម្បីការពារបេតិកភ័ណ្ឌជាតិដ៏ល្បីរុងរឿងរបស់ប្រទេសកម្ពុជាយើងជាមួយគ្នានេះដែរ យើងដឹងច្បាស់ថាការអភិវឌ្ឍន៍សេដ្ឋកិច្ចមានសារៈសំខាន់ណាស់ក្នុងការកែលំអរជីវភាពរស់នៅរបស់ប្រជាជនយើង។ ការពុះពារគ្រប់ឧបសគ្គដើម្បីបង្កើតឲ្យមានតុល្យភាពគឺជាការសំខាន់ហើយការសហការបំពេញការងារជាមួយអង្គការWWF គឺជាមធ្យោបាយដ៏សំខាន់ក្នុងការបង្កើតគោលនយោបាយគន្លឹះអំពីការអភិវឌ្ឍន៍បៃតងក្នុងគោលបំណងដឹកនាំប្រទេសកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព"។





## ការការពារសត្វផ្សោតទន្លេមេគង្គ

សត្វផ្សោតអ៊ីរ៉ាវ៉ាឌី (Orcaella brevirostris) ដែលកំពុងរងគ្រោះជិតផុតពូជមាននៅសេសសល់ក្នុងទន្លេមេគង្គក្នុងចំនួនសរុប ៨៥ ក្បាលប៉ុណ្ណោះ។ សត្វផ្សោតប្រភេទនេះត្រូវបានចាត់ទុកជាបេតិកភ័ណ្ឌជាតិមានជីវិតដោយរាជរដ្ឋាភិបាលកម្ពុជា ហើយវាជួយបង្កើនជីវភាពរស់នៅរបស់ប្រជាជនដែលរស់នៅតាមដងទន្លេមេគង្គតាមរយៈវិស័យទេសចរណ៍។ អង្គការ WWF គាំទ្ររាជរដ្ឋាភិបាលលើការពង្រឹងលើការអនុវត្តច្បាប់ការពារសត្វផ្សោតប្រភេទនេះ។

© Gerard Ryan/ WWF-Cambodia

សត្វផ្សោតទន្លេមេគង្គដែលរងគ្រោះថ្នាក់ជិតផុតពូជ ថតបាននៅភាគខាងជើងឈាងខាងកើត ខេត្តក្រចេះ ប្រទេសកម្ពុជា។ ចំនួនសត្វផ្សោតទន្លេមេគង្គមានប្រមាណចន្លោះពី ៦៦ ទៅ ៨៦ ក្បាលរស់នៅតាមបណ្តោយទន្លេមេគង្គប្រវែង ១៩០ គីឡូម៉ែត្រចន្លោះប្រទេសកម្ពុជា និងឡាវ។

# សកម្មភាពរួមគ្នាសម្រាប់ពេលអនាគត

## បញ្ឈប់ការសាងសង់ទំនប់វារីអគ្គីសនី ដន សាហុង

«២៦៨,០០០+ មនុស្សជិត២ម៉ឺន ៧សែននាក់ នៅទូទាំងពិភពលោកបាន ចូលរួមចុះញត្តិអេឡិច ត្រូនិចដើម្បីបញ្ឈប់គម្រោង សាងសង់ទំនប់វារីអគ្គីសនី ដន សាហុង»

ដើម្បីការពារ និងសង្គ្រោះសត្វផ្សោតអ៊ីរ៉ាវ៉ាឌីដែលនៅសេសសល់ចុងក្រោយនៅក្នុងទន្លេមេគង្គ និងការពារជីវភាពប្រជាជនរាប់លាននាក់ដែលពឹងអាស្រ័យលើប្រភពធនធានជលផល និង កសិកម្ម។ អង្គការ WWF ប្រចាំប្រទេសកម្ពុជាបានរៀបចំបង្កើតយុទ្ធនាការជាសកលមួយនាខែ ឧសភា ឆ្នាំ ២០១៤ កន្លងទៅនេះ ក្នុងគោលបំណងបញ្ឈប់ការសាងសង់ទំនប់វារីអគ្គិសនី ដន សាហុង ដ៏ចម្រូងចម្រាស់។ ប្រសិនបើទំនប់វារីអគ្គីសនី ដន សាហុង ដែលស្ថិតនៅតាមបណ្តោយទន្លេមេគង្គក្នុងចម្ងាយប្រមាណ ១គីឡូម៉ែត្រពីព្រំប្រទល់នៃប្រទេសកម្ពុជាត្រូវបានសាងសង់ វាមិនត្រឹមតែពន្លឿនការវិនាសផុតពូជនៃសត្វផ្សោតទន្លេមេគង្គប៉ុណ្ណោះទេ ប៉ុន្តែទំនប់នេះនឹងបិទចរន្តទឹកសមស្របតែមួយគត់សម្រាប់ការធ្វើចរាចរណ៍បំលាស់ទីរបស់ត្រីពេញមួយឆ្នាំ និងបង្កហានិភ័យដល់ប្រភពធនធានទឹកដ៏ធំជាងគេក្នុងពិភពលោក។

អង្គការ WWF បាននឹងកំពុងអំពាវនាវឲ្យមានការផ្អាកជាបណ្តោះអាសន្នលើការសាងសង់ទំនប់វារីអគ្គីសនី ដន សាហុង និងសូមឲ្យមានការរង់ចាំរហូតដល់មានការសិក្សាអំពីផលប៉ះពាល់ អត្ថប្រយោជន៍ និងការចំណាយដែលពាក់ព័ន្ធទៅនឹងការសាងសង់នេះត្រូវបានបំពេញឲ្យបានគ្រប់ជ្រុងជ្រោយ ដោយមានការចូលរួមដ៏សកម្មពីរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលក្នុងគោលបំណងធានាឲ្យបាននូវការអភិវឌ្ឍន៍អាងទន្លេមេគង្គក្រោមប្រកបដោយនិរន្តរភាព។

លោក ជេរ៉ាដ រ៉ាយអែន (Gerard Ryan) អ្នកនិពន្ធអត្ថបទវិទ្យាសាស្ត្រអំពីផលប៉ះពាល់ដែលអាចកើតមានដោយគម្រោងសាងសង់ទំនប់វារីអគ្គីសនី ដន សាហុង បានមានប្រសាសន៍ថា "នាយករបស់ក្រុមហ៊ុន មេហ្គាហ្វឹស (Mega First) មានជម្រើសពីរ ឬមួយត្រូវជ្រើសរើសទីតាំងផ្សេងដែលមិនប៉ះពាល់ដល់បរិស្ថាន និងស្វែងរកច្រកសមស្របសម្រាប់ការបំលាស់ទីរបស់ត្រី ឬមួយក៏បន្តគម្រោងដែលមានគុណវិបត្តិនេះហើយបំផ្លាញជិវិតសត្វផ្សោតទន្លេមេគង្គដែលកំពុងរងគ្រោះជិតផុតពូជ"។




© Thomas Cristofoletti / WWF-Cambodia

ព្រឹត្តិការណ៍ជាសាធារណៈរបស់អង្គការ WWF កម្ពុជា បានបង្ហាញពីការក្តីព្រួយបារម្ភរបស់ប្រជាជនច្រើនជាង ២សែន ៧ ម៉ឺននាក់ ដើម្បីស្នើសុំឲ្យក្រុមហ៊ុន មេហ្គាហ្វើស បញ្ឈប់ការសាងសង់ទំនប់វារីអគ្គីសនី ដន សាហុង នៅលើទន្លេមេគង្គ។

## យុវជនដឹកនាំមុខសម្រាប់ទិវាមួយម៉ោងសម្រាប់ភពផែនដី ឆ្នាំ ២០១៤



© Khem Chhor Vida / WWF-Cambodia

យុវជនខ្មែរចូលរួមប្រារព្ធទិវាមួយម៉ោងសម្រាប់ភពផែនដី នៅវិទ្យាស្ថានភាសាបរទេស IFL កាលពីដើមឆ្នាំ ២០១៤

នៅល្ងាចថ្ងៃទី ២៩ ខែ មីនា យុវជនជាង ១,០០០ នាក់បានអុចទៀនបំភ្លឺនៅវិទ្យាស្ថានភាសាបរទេសភ្នំពេញ ក្រោមការដឹកនាំរបស់សមាគមអតីតនិស្សិតអាហារូបករណ៍រដ្ឋថ្នាក់បរិញ្ញា និង និស្សិតអាហារូបករណ៍ហ្វូលប្រៃ នៃប្រទេសកម្ពុជា (FUSAAC) ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការ WWF។ ទិវាមួយម៉ោងសម្រាប់ភពផែនដីរបស់ប្រទេសកម្ពុជាឆ្នាំ ២០១៤ បានអំពាវនាវឲ្យយុវជនបង្ហាញពីការប្តេជ្ញាចិត្តរបស់ពួកគេក្នុងកិច្ចការពារភពផែនដី។ ក្រៅពីនិមិត្តរូបបិទភ្លើងមួយម៉ោងនោះ អ្នកចូលរួមទាំងអស់បានជួបជុំគ្នាចែករំលែកពីក្តីព្រួយបារម្ភណ៍របស់ ខ្លួ ន លើបរិស្ថាន ហើយបង្ហាញប្រាប់ឲ្យដឹងថាតើពួកគេអាចប្រើសិទ្ធអំណាចរបស់ខ្លួនដោយរបៀបណាដើម្បីបំពេញសកម្មភាពដ៏មានអត្ថន័យជួយដល់ភពផែន ដី និងបរិស្ថានប្រទេសកម្ពុជាយើង។

# ចំនូល និង ចំណាយកម្មវិធីរបស់អង្គការ WWF-កម្ពុជា ២០១៣ - ២០១៤

## ចំណូលរបស់កម្មវិធី
USD 6,030,516




## ចំណាយរបស់កម្មវិធី
USD 4,249,289




## របាយការណ៍ចំណូល និង ចំណាយឆ្នាំ ២០១៣-២០១៤

ចាប់ពីខែ កក្កដា ឆ្នាំ ២០១៣ ដល់ខែ មិថុនា ឆ្នាំ២០១៤ អង្គការ WWF មានថវិកាសរុបចំនួន៦,០៣០,៥១៦ ហើយចំណាយអស់ចំនួន៤,២៤៩,២៨៩ ទៅលើការប្រតិបត្តិការ និងទៅលើកម្មវិធីរបស់តំបន់ទេសភាពស៊ីផាន់ដន-ស្ទឹងត្រែង-ក្រចេះ និងតំបន់ទេសភាពខ្ពង់រាបភាគខាងកើត ក៏ដូចជាទៅលើគម្រោងអភិវឌ្ឍន៍បែតងរបស់ផ្តៅ។

# តួរលេខរបស់អង្គការ WWF-កម្ពុជា

## ២,៧០០-៥,៧០០

ប្រទេសកម្ពុជាមានចំនួនសត្វទន្សោងដែល
រងគ្រោះជិតផុតពូជច្រើនជាងគេបំផុតនៅ
លើសកលលោក

## ២៦៨,២៩៤

សម្លេងរបស់ប្រជាជនទូទាំងពិភពលោកឲ្យ
បញ្ឈប់ទំនប់វារីអគ្គិសនី ដន សាហុង



## ២៥,០០០+

ចំនួនសមាជិកបណ្តាញហ្វេប៊ុកថ្មី

## ១,១២០

សហគមន៍បានប្រមូលផលដើមផ្តៅ
ចំនួនរាប់តោន ដែលក្នុងនោះ ៥០%
បានផ្គត់ផ្គង់ទៅឲ្យសមាគមផ្តៅកម្ពុជា។

## ១៣

ប្រភេទសត្វថ្មីដែលបានរកឃើញ
នៅក្នុងប្រទេសកម្ពុជា

Why we are here
To stop the degradation of the planet's natural environment and to build a future in which humans live in harmony with nature.
panda.org

© 1986 Panda symbol WWF – World Wide Fund For Nature (Formerly World Wildlife Fund)
® "WWF" is a WWF Registered Trademark. WWF, Avenue du Mont-Blanc, 1196 Gland, Switzerland – Tel. +41 22 364 9111 Fax +41 22 364 0332. For contact details and further information, please visit our international website at www.panda.org

**WWF-Cambodia**
21 Street 322, Boeung Keng Kang I,
Chamkar Mom, Phnom Penh, Cambodia
Tel: +855 23 218 034
Fax: +855 23 211 909
Email: wwfcambodia@wwfgreatermekong.org